**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋាន កងរាជអាវុធហត្ថ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបង្កើតស្នងការដ្ឋានចំនួន ០៥ ដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដូចខាងក្រោម :

១- ស្នងការដ្ឋានព័ត៌មាន និងសន្តិសុខ

២- ស្នងការដ្ឋានផែនការប្រតិបត្តិការ

៣- ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌

www.pheakdeylaw.com

៤-ស្នងការដ្ឋានប្រភពកម្លាំង

៥-ស្នងការដ្ឋានភស្តុភារ និងបច្ចេកទេស

**មាត្រា ២ :** ស្នងការដ្ឋានខាងលើមានឋានៈស្មើនាយកដ្ឋាន ។

**មាត្រា ៣ :** តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងក្របខ័ណ្ឌចាត់តាំងរបស់ស្នងការដ្ឋាន អាស្រ័យដោយក្រសួងការពារជាតិកំណត់ ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ... ឆ្នាំ២០០៩




**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានឃើញសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**



**នាយឧត្ដមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៥

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

សច្ចាប័ន : ថ្ងៃទី២៥ ខែ ៧ ឆ្នាំ២០០៩
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំងកងរាជអាវុធហត្ថ
នាយករដ្ឋមន្ត្រី
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# រចនាសម្ព័ន្ធចាត់តាំងកងរាជអាវុធហត្ថ

- មេបញ្ជាការ ១
- មេបញ្ជាការរង ៣
  - នាយសេនាធិការ
    - ស្នងការព័ត៌មាននិងសន្តិសុខ
    - ស្នងការផែនការប្រតិបត្តិការ
    - ស្នងការស្រាវជ្រាវនិងយុត្តិធម៌
    - ស្នងការបុគ្គលកម្លាំង
    - ស្នងការភស្តុភារនិងបច្ចេកទេស

បានឃើញសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**